ព្រះគម្ពីរសំរាប់កុមារ
សូមបង្ហាញជូន

# បុណ្យព្រះ
# យេស៊ូវរស់ឡើងវិញពី
# សេចក្តីស្លាប់ជា
# លើកដំបូង



និពន្ធដោយៈ Edward Hughes

ធ្វើការពន្យល់ដោយៈ Janie Forest
Alastair Paterson

កែសម្រួលដោយៈ Lyn Doerksen

បកប្រែដោយៈ www.christian-translation.com

ផលិតដោយៈ Bible for Children
www.M1914.org

©2020 Bible for Children, Inc.
អាជ្ញាប័ណ្ណៈ លោកអ្នកមានសិទ្ធិក្នុងការថតចម្លង ឬបោះពុម្ពរឿងនេះបាន
តែលោកអ្នកមិនអាចយកវាទៅលក់បានទេ។

ស្ត្រីម្នាក់បានឈរនៅក្បែរ
ភ្នំដ៏អ៊ូរអរ ក្អែកពោរពេញ
ដោយសេចក្តីទុក្ខព្រួយ សំ
លឹងមើលទៅទិដ្ឋភាពដ៏
គួរអោយរន្ធត់។ កូន
របស់គាត់កំពុងជិត
បាត់បង់ជីវិត។ ម៉ារី
ជាម្តាយបានឈរនៅ
ជិតកន្លែងដែលព្រះ
យេស៊ូត្រូវបានគេដំ
ដែកគោលភ្ជាប់
ទៅនឹងឈើ
ឆ្កាង។





តើរឿងទាំងនេះកើតឡើង
បានយ៉ាងដូចម្ដេចទៅ? ហេតុ
ដូចម្ដេចបានជាព្រះយេស៊ូ
បញ្ចប់ជីវិតដ៏ស្រស់ស្អាតរបស់
ទ្រង់ក្នុងសភាពដ៏
អាក្រក់បែបនេះ?
ហេតុអ្វីបានជា
ព្រះជាម្ចាស់
អនុញ្ញាតអោយគេដំដែក
គោលព្យួរព្រះបុត្រារបស់ទ្រង់
ទៅនឹងឈើឆ្កាងដើម្បីបញ្ចប់
ជីវិតនៅទីនោះ? តើព្រះយេស៊ូ
ភាន់ច្រឡំពីអត្តសញ្ញាណរបស់
ទ្រង់ឬ? តើព្រះជាម្ចាស់
បានបរាជ័យហើយឬ?



ទេ! ព្រះជាម្ចាស់មិនបាន
បរាជ័យទេ។ ព្រះយេស៊ូក៏
មិនបានភាន់ច្រឡំអ្វីដែរ។
ព្រះយេស៊ូបានដឹងជានិច្ចថា
ទ្រង់នឹងត្រូវសុគត
ដោយសារមនុស្សអាក្រក់។
សូម្បីតែពេលដែលព្រះយេស៊ូ
នៅជាទារកនៅឡើយ បុរស
ចំណាស់ម្នាក់ឈ្មោះ សាយ
មិន ក៏បានប្រាប់ម៉ារីថា ក្តី
ទុក្ខព្រួយនឹងកើតមាន
ឡើងនៅពេលខាងមុខ។



ពីរបីថ្ងៃ
មុនពេលដែលព្រះ
យេស៊ូត្រូវបានគេធ្វើគុត
ស្ត្រីម្នាក់បានមក ហើយ
ចាក់ប្រេងទឹកអប់លើព្រះ
បាតរបស់ទ្រង់។ ពួកសិស្ស
បានរអ៊ូរទាំថា “ស្ត្រីម្នាក់នេះ
កំពុងខ្ជះខ្ជាយប្រាក់របស់
គាត់ហើយ”។ ព្រះយេស៊ូបានមានព្រះ
បន្ទូលថា “ស្ត្រីម្នាក់នេះធ្វើបាន
ល្អណាស់, គាត់ធ្វើនេះសំរាប់ជាកិច្ចបញ្ចុះ
សពរបស់យើង។” នេះជាព្រះបន្ទូលដ៏ថម្លៃកណាស់!

ក្រោយពីនោះមក យូដាស
ដែលជាកូនសិស្សម្នាក់ក្នុង
ចំណោមសិស្សទាំង១២នាក់
របស់ព្រះយេស៊ូ បានយល់ព្រម
ជាមួយពួកប្រធានសង្ឃក្បត់
នឹងព្រះយេស៊ូ ដោយទទួល
បានដុំប្រាក់ ចំនួន៣០ដុំ។





នៅពិធីបុណ្យរំលងរបស់សាសន៍ជ្វីហ្វ
ព្រះយេស៊ូបានសោយភោជនាហារចុង
ក្រោយរបស់ទ្រង់ជាមួយពួកសិស្សរបស់
ទ្រង់។ ទ្រង់បានប្រាប់ពួកគេពីរឿងអ
ស្ចារ្យរបស់ព្រះជាម្ចាស់ និងការសន្យា
របស់ទ្រង់ចំពោះអ្នកដែលស្រលាញ់ទ្រង់។
បន្ទាប់មក ព្រះយេស៊ូបានប្រទាននំបុ័ង
និងទឹកមួយពែងចែករំលែកដល់ពួក
គេ។ ទាំងនេះជាការរំលឹកដល់
ពួកគេថាព្រះយេស៊ូ
ប្រទានព្រះកាយ
និងព្រះលោហិត
របស់ទ្រង់ដើម្បីទទួល
បានការអភ័យទោស
ចំពោះអំពើបាប។

ក្រោយមក ព្រះយេស៊ូបានប្រាប់មិត្តរបស់ទ្រង់ថា មាន
មនុស្សក្បត់ទ្រង់ ហើយពួកគេនឹងរត់ចោលទ្រង់។ ភីតផើ
បានបញ្ជាក់ហើយបញ្ជាក់ទៀតថា “ទោលបង្គំមិនរត់ចោល
ទ្រង់ទេ”។ ព្រះយេស៊ូបានមានព្រះបន្ទូលថា“មុនពេល
មាន់រងាវ អ្នកនឹងបដិសេធនឹងយើងចំនួនពាដង”។





ក្រោយមកនៅយប់នឹង ព្រះយេស៊ូបានយាងទៅ បួងសួងនៅក្នុងសួន ហ្គិតសេមេន។ ពួកសិស្ស ដែលនៅជាមួយទ្រង់បាន ដេកលក់អស់។ ព្រះយេស៊ូ បានបួងសួង “ឱ ព្រះវរ បិតានៃទូលបង្គំអើយ... សូមអោយពែងនេះឆ្លង កាត់ពីទូលបង្គំទៅ។ ប៉ុន្តែ សូមកុំអោយកើតឡើង តាមចិត្តរបស់ទូលបង្គំ ឡើយ សូមកើតឡើង តាមព្រះហឫទ័យរបស់ ទ្រង់វិញ។”

រំពេចនោះ ហ្វូងមនុស្សកកកុញបានចូលមកក្នុង
សួន, ដឹកនាំដោយពួកយូដាស។ ព្រះយេស៊ូមិនបាន
រឹងទទឹងឡើយ ប៉ុន្តែ ភីតធើវិញបានកាត់ត្រចៀក
របស់បុរសម្នាក់ចោល។ ព្រះយេស៊ូបានប៉ះត្រចៀក
បុរសម្នាក់នោះដោយស្ងៀមស្ងាត់
ហើយបានព្យាបាលគាត់។ ព្រះ
យេស៊ូបានដឹងថាការចាប់
ខ្លួនរបស់ទ្រង់គឺជាផ្នែក
មួយនៃបំណងរបស់ព្រះ
ជាម្ចាស់។



មនុស្សទាំងនោះបាននាំព្រះយេស៊ូទៅផ្ទះរបស់សម្ដេចសង្ឃ។
នៅពេលនោះ មេដឹកនាំជូហ្វបាននិយាយថា ព្រះយេស៊ូគួរតែ
សុគត។ នៅជិតនោះ ភីត
ធើបានឈរជិតភ្លើងរបស់
អ្នកបម្រើ ហើយ
សំលឹងមើល។



មនុស្សបីនាក់បានសំលឹងមើលភីតធើដោយមិនដាក់ភ្នែក ហើយបាននិយាយថា “អ្នកអែងនៅជាមួយនឹងព្រះយេស៊ូ!”
ភីតធើបានប្រកែកចំនួន ៣ដង
ដូចដែលព្រះយេស៊ូបាន
មានបន្ទូល។ ភីតធើ
បានជេរដាក់បណ្ដា
សា ហើយបានទាំង
ស្បថស្បែរទៀតផង
ថាមិនបាននៅ
ជាមួយព្រះយេស៊ូ។



# ក្ពុក-កាក-ក្ពុក-ក្ពុក



ក្រោយមក មាន់បានរងាវ។
ដូចជាសំលេងព្រះជាម្ចាស់ទៅ
កាន់ភីតផើ។ ភីតផើបានចង
ចាំពាក្យរបស់ព្រះយេស៊ូ ហើយ
បានទ្រហរយំយ៉ាងខ្លាំង។



យូដាសក៏មានអារម្មណ៍សោក
ស្តាយដែរ។ គេបានដឹងថាព្រះ
យេស៊ូមិនបានប្រព្រឹត្តអំពើ
បាប ឬឧក្រិដ្ឋកម្មណាមួយឡើ
យ។ យូដាសបានយកដុំប្រាក់
៣០ដុំទៅអោយពួកសង្ឃវិញ
តែពួកគេមិនយក។



យូដាសបានបោះដុំ
លុយទាំងនោះចោល,
ដើរចេញទៅ-ហើយ
ចងកសំលាប់ខ្លួន។



ពួកសង្ឃបាននាំព្រះយេស៊ូ
ទៅជួប ពីឡាត់, ដែលជា
អភិបាលរបស់ពួកសាសន៍
រ៉ូម។ ពីឡាត់បាននិយាយ
ថា “បុរសម្នាក់នេះមិន
មានកំហុសអ្វីទេ។” ប៉ុន្តែប
ណ្ដាជនចេះតែបន្តស្រែក
ថា “ឆ្កាងគេទៅ! ឆ្កាងគេ
ទៅ!”

ទីបំផុត ពីឡាត់បានសុខចិត្តធ្វើស្របតាម
អ្វីដែលបណ្តាជនចង់បាន ហើយបានដាក់
ទោសព្រះយេស៊ូអោយស្លាប់លើឈើឆ្កាង។
ពួកទាហានបានដាល់ព្រះយេស៊ូ, ស្តោះទឹក
មាត់ដាក់ព្រះភក្រ័ព្រះអង្គ ហើយវាយព្រះ
កាយទ្រង់។ ពួកគេបានធ្វើម្កុដដ៏សាហាវ
មួយចេញពីមែកបន្លាដែលមុតស្រួចវែង
ហើយបានសង្កត់វាលើព្រះសិរសាររបស់ទ្រ
ង់។ បន្ទាប់មក ពួកគេបានដំដែកគោល
ទ្រង់ទៅនឹងឈើឆ្កាងរហូត
ដល់សោយទិវង្គត់។





ព្រះយេស៊ូទ្រង់បានដឹងជានិច្ចហើយថាទ្រង់នឹងសុគតរបៀប
នេះ។ ទ្រង់ក៏បានដឹងផងដែរថា ការសុគតរបស់ទ្រង់នឹងនាំ
មកនូវការអភ័យទោសសំរាប់ជនអ្នកប្រព្រឹត្តអំពើបាបដែល
បានដាក់ជំនឿរបស់ពួកគេលើទ្រង់។
ឧក្រិដ្ឋជន២នាក់ត្រូវបានឆ្កាង
នៅជិតព្រះយេស៊ូ។ ម្នាក់ដែល
មានជំនឿលើព្រះយេស៊ូ គាត់
បានឡើងទៅលើឋានសួគ៌។
ហើយម្នាក់ទៀតដែលមិនជឿ
លើព្រះយេស៊ូ មិនបានឡើង
ទៅឋានសួគ៌ទេ។



បន្ទាប់ពីទទួលការរងទុក្ខជាច្រើន
ម៉ោងហើយនោះ, ព្រះយេស៊ូបាន
មានបន្ទូលថា “វាចប់ហើយ”
ហើយទ្រង់ក៏សុគតទៅ។
ការងាររបស់ទ្រង់បាន
ចប់សព្វគ្រប់ហើយ។
មិត្តទ្រង់បានបញ្ចុះ
សពទ្រង់ក្នុងផ្នូរ
ឯកជនមួយ។



បន្ទាប់មកពួក
ទាហានរ៉ូមបានឡោម
ព័ទ្ធ ហើយបានយាម
ផ្នូរនោះ។ ពេលនេះ
គ្មាននរណាម្នាក់អាច
ចេញចូលបានទេ។



ប្រសិនបើនេះជាទីបញ្ចប់
របស់សាច់រឿង មិនដឹង
ជាកំសត់ប៉ុន្នាទេ។ ប៉ុន្តែ
ព្រះជាម្ចាស់បានធ្វើអ្វី
ម៉្យាងដែលអស្ចារ្យ។ ព្រះ
យេស៊ូមិនបានបន្តជា
សាកសពនោះទេ!



នាពេលព្រឹកព្រលឹមនៅថ្ងៃទីមួយក្នុង
សប្តាហ៍នោះ, ពួកសិស្សរបស់ព្រះ
យេស៊ូមួយចំនួនបានឃើញ
ថាដុំថ្មបានរមៀលចេញពី
ផ្នូរ។ នៅពេលដែលពួក
គេសំលឹងមើលនៅ
ខាងក្នុង គេមិន
ឃើញព្រះ
យេស៊ូនៅទីនោះ
ទៀតឡើយ។



ព្រះយេស៊ូបានលេចឡើងចំពោះមុខស្ត្រីម្នាក់ ដែលគាត់បាននៅបន្ទយំនៅជិតផ្នូររបស់ទ្រង់។ បន្ទាប់ពីបានឃើញព្រះយេស៊ូ គាត់បានប្រញាប់ប្រញាលត្រលប់ទៅប្រាប់ពួកសិស្សដទៃទៀតយ៉ាងសប្បាយរីករាយ។ “ព្រះយេស៊ូនៅមានជីវិត!



ព្រះយេស៊ូបាន
រស់ឡើងវិញពីសេចក្តីស្លាប់!”

មិនយូរប៉ុន្មាន ព្រះយេស៊ូបានទៅជួបពួកសិស្ស
របស់ទ្រង់ ហើយបានបង្ហាញពួកគេនូវស្នាមដែក
គោលនៅនឹងដៃទ្រង់។ វាជាការពិត ព្រះយេស៊ូមាន
ជីវិតម្តងទៀត! ទ្រង់លើកទោសអោយភីតធើដែល
បានបដិសេធថាមិនបាននៅជាមួយទ្រង់ ហើយ
ទ្រង់បានប្រាប់ពួកសិស្សទ្រង់អោយប្រាប់ទៅគ្រប់
គ្នាអំពីទ្រង់។ បន្ទាប់មកទ្រង់បានយាងត្រលប់
ទៅឋានសួគ៌វិញដែលជាទីកន្លែងដែល
ទ្រង់បានយាងមកនោះ។

បុណ្យព្រះយេស៊ូរស់ឡើងវិញពីសេចក្ដីស្លាប់ជាលើកដំបូង

រឿងមួយពីព្រះបន្ទូលរបស់ព្រះជាម្ចាស់, ព្រះគម្ពីរ,

អាចរកឃើញនៅក្នុង

ម៉ាថាយ ២៦-២៨, លូកា ២២-២៤,
យ៉ូហាន ១៣-២១

“ការបើកសម្ដែងនូវព្រះបន្ទូលទ្រង់ផ្ដល់នូវពន្លឺ។”
ទំនុកតម្កើង ១១៩៖ ១៣០

មប់

រឿងព្រះគម្ពីរនេះប្រាប់យើងពីព្រះជាម្ចាស់ដ៏អស្ចារ្យរបស់
យើងដែលបានបង្កើតយើងមក ហើយចង់អោយអ្នកស្គាល់ទ្រង់។

ព្រះអង្គជ្រាបថា យើងបានប្រព្រឹត្តអំពើអាក្រក់, ដែលទ្រង់ហៅការទាំងនោះថាជា អំពើបាប។ ទោសនៃអំពើបាបគឺសេចក្តីស្លាប់, ប៉ុន្តែព្រះទ្រង់ស្រឡាញ់យើងខ្លាំងណាស់ ដល់ម្ល៉េះហើយបានជាទ្រង់បានចាត់ព្រះយេស៊ូដែលជាព្រះរាជបុត្រាតែមួយរបស់ព្រះអង្គអោយមកសុគតនៅលើឈើឆ្កាង ហើយបង់ថ្លៃនៃទោសនោះជំនួសយើង។ ព្រះយេស៊ូបានរស់ពីសុគតឡើងវិញ ហើយបានយាងត្រលប់ទៅស្ថានសួគ៍! ប្រសិនបើអ្នកជឿលើព្រះយេស៊ូ ហើយសុំទ្រង់អោយអភ័យទោសចំពោះអំពើបាបរបស់អ្នក, ទ្រង់នឹងលើកលែងទោសអោយអ្នក! ទ្រង់នឹងមក ហើយរស់ក្នុងចិត្តរបស់អ្នកឥឡូវនេះ, ហើយអ្នកនឹងរស់នៅជាមួយទ្រង់ជារៀងរហូត។

ប្រសិនបើអ្នកជឿថានេះជាការពិត, អ្នកត្រូវទូលទៅកាន់ព្រះអង្គថា៖ ឱព្រះយេស៊ូទូលបង្គំជឿហើយថាទ្រង់ជាព្រះ ហើយបានក្លាយជាមនុស្សម្នាក់មកដើម្បីសុគតជំនួសអំពើបាបរបស់ទូលបង្គំ, ហើយពេលនេះទ្រង់រស់ពីសុគតឡើងវិញ។ សូមទ្រង់យាងចូលក្នុងជីវិតរបស់ទូលបង្គំ ហើយអភ័យទោសចំពោះអំពើបាបរបស់ទូលបង្គំ ដើម្បីទូលបង្គំអាចមានជីវិតថ្មីនាពេលឥឡូវនេះបាន ហើយថ្ងៃមួយទូលបង្គំនឹងទៅនៅជាមួយទ្រង់ជារៀងរហូត។ សូមជួយទូលបង្គំអោយគោរពទ្រង់ហើយរស់នៅសំរាប់ទ្រង់ដូចជាបុត្ររបស់ទ្រង់។ អាម៉ែន។

សូមអានព្រះគម្ពីរ ហើយអធិដ្ឋានទៅព្រះជារៀងរាល់ថ្ងៃ!   យ៉ូហាន ៣៖១៦